អង្គការ យេនឌ័រ និង អភិវឌ្ឍន៍ ដើម្បីកម្ពុជា
Gender and Development for Cambodia

លេខ ០៤៥៧/០៥.GAD/C/05 ភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ២០០៥

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា**

**កម្មវត្ថុ: ស្តីពីយុទ្ធនាការ ១៦ថ្ងៃ បូពណ៌ស ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ ។**

ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរព !

ចាប់ពីថ្ងៃទី ២៥ វិច្ឆិកា រហូតដល់ថ្ងៃទី ១០ ធ្នូ ជារៀងរាល់ឆ្នាំ នៅប្រទេសជាច្រើនលើពិភពលោកបាន រៀបចំយុទ្ធនាការដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីដែលមានរយៈពេល១៦ថ្ងៃ។ ដោយឡែកនៅប្រទេសកម្ពុជា ឆ្នាំនេះគឺជាឆ្នាំទី៦ ដែលអង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) សហការជាមួយ បណ្តាញបុរស កម្ពុជា (CMN) និងបណ្តាញយេនឌ័រនិងអភិវឌ្ឍន៍(GADNet) អង្គការក្រៅរដ្ឋាភិបាល ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃនិងស្ថាប័នពាក់ព័ន្ធនានានិងអាជ្ញាធរដែនដីនឹងធ្វើ ***យុទ្ធនាការ១៦ថ្ងៃ បូពណ៌ស*** ដែលមាន គោលបំណងដើម្បីបង្កើនការយល់ដឹងពីបញ្ហាអំពើហិង្សាប្រឆាំងស្ត្រី និងកុមារ នៅក្នុងសហគមន៍។

យុទ្ធនាការនេះនឹងបង្កើនការយល់ដឹងពី ឬសគល់ បុព្វហេតុនៃអំពើហិង្សាប្រឆាំងស្ត្រី និងកុមារ និង ការទទួលស្គាល់នូវការផ្លាស់ប្តូរតួនាទីបុរសក្នុងការប្រយុទ្ធប្រឆាំងបញ្ហាអំពើហិង្សាលើស្ត្រី និងកុមារ នៅក្នុង សហគមន៍ ប្រធានបទឆ្នាំនេះគឺផ្តោតទៅលើ *" សុខភាពស្ត្រី ជាសុខភាពពិភពលោក គ្មានអំពើហិង្សា "* ដែលជាប្រធានបទសកល និងមានខ្លឹមសារដូចខាងក្រោម :

១. អំពើហិង្សាប្រឆាំងស្ត្រីគឺធ្វើឱ្យរបួសដល់រាងកាយ ផ្លូវចិត្ត និងបញ្ញាស្មារតីរបស់ស្ត្រីដែលជាឧបសគ្គ រារាំងមិនឱ្យស្ត្រីចូលរួមយ៉ាងសកម្មក្នុងការងារអភិវឌ្ឍន៍គ្រួសារ សហគមន៍ និងពិភពលោកបាន។

២. អំពើហិង្សាលើស្ត្រី គឺជាការកំរិតលទ្ធភាពរបស់ស្ត្រី ដើម្បីចូលរួមក្នុងការការពារនៃការចំលង មេរោគ និងឱកាសទទួលបានពត៌មានផ្នែកសុខភាព និងសេវាកម្ម ដែលមានសារៈសំខាន់នានា រួមទាំងការពិនិត្យ និងព្យាបាលសុខភាពផងដែរ។

ផ្ទះលេខ ៤ ផ្លូវ ២៩៤ សង្កាត់ ទន្លេបាសាក់ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រប្រៃសណីយ៍ ២៦៨៤, ប្រអប់សំបុត្រ ស៊ីស៊ីស៊ី ១២៨, ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ២១៥ ១៣៧, អ៊ីម៉ែល: gad@online.com.kh
វែបសាយ: http://www.online.com.kh/~gad

៣. ប្រសិនបើអ្នកអត់ឱនអោយអ្នកដែលប្រព្រឹត្តអំពើហិង្សាលើស្ត្រីមានន័យថា អ្នកក៏កំពុងសមគំនិតជាមួយអ្នកដែលប្រព្រឹត្តអំពើហិង្សានោះ ឬប្រសិនបើអ្នកនៅស្ងៀមមិនអើពើចំពោះអំពើហិង្សាលើស្ត្រីមានន័យថា អ្នកក៏កំពុងប្រព្រឹត្តអំពើហិង្សាលើស្ត្រីដែរ ។

៤. អំពើហិង្សាលើស្ត្រី វាបង្កើនភាពងាយរងគ្រោះរបស់ស្ត្រី ក្នុងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ។

**យើងធ្វើការផ្សព្វផ្សាយពតិមាននេះ តារយៈការធ្វើសកម្មភាពមួយចំនួនដូចជា ៖**

- ហែរក្បួននៅតាមដងផ្លូវសាធារណៈ ទៅដល់ផ្ទះ និងភូមិមួយចំនួនរបស់ប្រជាពលរដ្ឋ ក្នុងប្រទេសកម្ពុជា ដើម្បីបំពាក់បូពណិស ចែកខិតបណ្ណ័ស្តីពីអត្ថន័យ និងខ្លឹមសារនៃបូពណិស និងផ្សព្វផ្សាយអំពីពតិមានដែលទាក់ទងនឹងប្រធានបទខាងលើ ។
- ផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍អំពីសកម្មភាពយុទ្ធនាការ ។
- កិច្ចពិភាក្សាតុមូលស្តីពីអត្ថន័យ ខ្លឹមសារ និងលទ្ធផលនៃយុទ្ធនាការបូពណិស ទាំង១៦ថ្ងៃ នូវទូទាំងប្រទេសតាមរយៈវិទ្យុ និងទូរទស្សន៍ ។

ភ្ជាប់ជាមួយនឹងសេចក្តីជូនដំណឹងនេះ យើងខ្ញុំសូមថ្លែងអំណគុណយ៉ាងជ្រាលជ្រៅចំពោះការសហការ និងការគាំទ្រ និងសូមផ្ញើជូននូវអត្ថន័យទាំងស្រុងនៃយុទ្ធនាការ បូពណិស ខិតប័ណ្ណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ដើម្បីទុកជាការរួមចំណែកក្នុងយុទ្ធនាការនេះ និងការបែងចែកពតិមានសំភារៈនេះដល់បុគ្គលិកទាំងអស់ក្នុងការប្តេជ្ញាចិត្តផ្ទាល់ខ្លួនរបស់គេ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និង កុមារ គ្រប់បែបយ៉ាង ។

យើងខ្ញុំសូមប្រសិទ្ធពរជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាប្រកបដោយសុខភាពល្អ និង ទទួលបាននូវជោគជ័យថ្មីៗទៀតកុំបីខានឡើយ ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទទួលយកនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

អង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា

នាយិកាប្រតិបត្តិ

រស់ សុភាព

- ជូនភ្ជាប់មកជាមួយនូវ តារាងកម្មវិធីសកម្មភាព កាលបរិច្ឆេទ និងទីកន្លែង

ផ្ទះលេខ ៤ ផ្លូវ ២៩៤ សង្កាត់ ទន្លេបាសាក់ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រប្រៃសណីយ៍ ២៦៨៤, ប្រអប់សំបុត្រ ស៊ីស៊ីស៊ី ១២៨, ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ២១៥ ១៣៧, អ៊ីម៉ែល: gad@online.com.kh
វែបសាយ: http://www.online.com.kh/~gad